ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

# គោលការណ៍ណែនាំ
# ស្តីពីការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅទីផ្សារ

# GUIDELINES ON AGRICULTURAL PRODUCTS TO MARKET LINKAGE



**រៀបចំដោយ** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ( ASPIRE )
**ឧបត្ថម្ភដោយ** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម ( IFAD )

IFAD
Investing in rural people

រាជធានីភ្នំពេញ ខែវិច្ឆិកា ឆ្នាំ ២០១៨

# អារម្ភកថា

ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ទេរនូវចំណេះដឹង បច្ចេកវិទ្យា និងការអនុវត្តន៍ថ្មីៗ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ។ ការផ្សព្វផ្សាយនេះរួមចំណែកក្នុងការដោះស្រាយគ្រោះធម្មជាតិ និងបញ្ហានានា ដល់កសិករ និងសហគមន៍កសិកម្ម សំដៅជំរុញ ការបង្កើនផលិតភាព គុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងបង្កើនប្រាក់ចំណូលគ្រួសារ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញនូវគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា នាឆ្នាំ ២០១៥ បានបង្ហាញថា ការផ្សព្វផ្សាយកសិកម្មត្រូវផ្លាស់ប្តូរយុទ្ធសាស្ត្រចេញពីការផ្សព្វផ្សាយដែលជម្រុញដោយផ្នែកផ្គត់ផ្គង់ ដើម្បីផលិតកម្មទៅរកការផ្សព្វផ្សាយដើម្បីតម្រូវការទីផ្សារ។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) បានរៀបចំ "**គោលការណ៍ណែនាំ ស្តីពីការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅទីផ្សារ**" នេះឡើង ដោយបានរៀបចំជាសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម អ្នកឯកទេស និងអ្នកពាក់ព័ន្ធមកពីស្ថាប័ន និងអង្គភាពផ្សព្វផ្សាយកសិកម្ម អង្គភាពជំនាញបច្ចេកទេសនានា ដែលមកពីគម្រោង PADEE, AIM និងកម្មវិធី ASPIRE ។

ឯកសារគោលការណ៍ណែនាំនេះ ជាមូលដ្ឋានគ្រឹះដែលពិព័ណ៌នាពី ជំហាននៃការចងក្រងបណ្តុំអាជីវកម្មកសិកម្មសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយឆ្លើយតបទៅនឹងតម្រូវការទីផ្សារប្រកបដោយប្រសិទ្ធភាព ដែលជួយដល់មន្ត្រីបច្ចេកទេស មន្ត្រីផ្សព្វផ្សាយកសិកម្មស្រុក និងភ្នាក់ងារផ្សព្វផ្សាយនៅមូលដ្ឋាននានា យកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេស ដើម្បីផ្ទេរចំណេះដឹង ព័ត៌មាននិងបច្ចេកវិទ្យាកសិកម្មដល់ប្រជាកសិករ និងប្រតិបត្តិករក្នុងកម្មវិធីផ្សព្វផ្សាយកសិកម្ម និងគម្រោងអភិវឌ្ឍកសិកម្មនានានៅកម្ពុជា។

អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមដាក់ចេញនូវគោលការណ៍ណែនាំ និងស្តីពីការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅទីផ្សារ ដែលជាឯកសារគ្រឹះសម្រាប់មន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យា និងវិធីសាស្ត្រ រួមចំណែកដល់ផលិតកម្មរបស់កសិករខ្នាតតូច តម្លៃនៃការលក់ផលិតផល និងកំណើនប្រាក់ចំណេញ។

ថ្ងៃ សុក្រ ៨ រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...៣០.....ខែ...វិច្ឆិកា.....ឆ្នាំ២០១៨

**អគ្គនាយកដ្ឋានកសិកម្ម**

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........................................ 1

វិធីសាស្រ្តរួម ........................................ 2

ដំណើរការ ........................................ 4

១. ការចុះសិក្សាតម្រូវការទីផ្សារ និងការវិភាគ........................................ 4

២. ការប្រជុំ និងពិភាក្សាជាមួយតួអង្គនៅក្នុងខ្សែច្រវាក់តម្លៃ ........................................ 6

៣. ការបង្កើតជាបណ្តុំផលិត (Clusters) និងរចនាសម្ព័ន្ធ ........................................ 7

៤. រៀបចំវេទិកាពហុភាគីពាក់ព័ន្ធ ( MSP-Multi Stakeholder Platform Meeting ) ........................................ 7

៥. រៀបចំកិច្ចសន្យារវាង អ្នកផលិត និងឈ្មួញ ........................................ 8

៦. គាំទ្រការអនុវត្តបណ្តុំ (មានកញ្ចប់ថវិកាជួយដល់យន្តការនេះ) ........................................ 8

៧. តាមដាន និងវាយតម្លៃ ........................................ 9

៨. តួនាទី និងភារកិច្ចរបស់មន្ត្រីជំនាញ........................................ 10

## សេចក្តីផ្តើម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញនូវគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជានាឆ្នាំ២០១៥ បានបង្ហាញថា ការផ្សព្វផ្សាយកសិកម្មត្រូវផ្លាស់ប្តូរយុទ្ធសាស្ត្រចេញពីការផ្សព្វផ្សាយដែលជម្រុញដោយផ្នែកផ្គត់ផ្គង់ ដើម្បីផលិតកម្មទៅរកការផ្សព្វផ្សាយដើម្បីតម្រូវការទីផ្សារ។ អនុលោមទៅតាមកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលសេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្មត្រូវធ្វើវិមជ្ឈការនៅថ្នាក់មូលដ្ឋាន ដោយពង្រឹងសមត្ថភាពមន្ត្រីនៅថ្នាក់ស្រុកនិងថ្នាក់ឃុំ ជាពិសេសលើការងារធ្វើផែនការ និងការសម្របសម្រួលខ្សែច្រវាក់តម្លៃកសិកម្ម។

គោលការណ៍ណែនាំនេះ ត្រូវបានបង្កើតឡើងដោយផ្អែកលើបទពិសោធន៍នៃវិធីសាស្ត្រអភិវឌ្ឍន៍បណ្តុំអាជីវកម្មកសិកម្ម ដែលផ្តួចផ្តើមដោយគម្រោងអភិវឌ្ឍវិស័យកសិកម្ម និងជម្រុញកំណើនសេដ្ឋកិច្ច (PADEE) ដែលគាំទ្រថវិកាដោយ IFAD ។វិធីសាស្ត្រនេះត្រូវបានបង្កើត និងសាកល្បងដោយជោគជ័យលើបណ្តុំអាជីវកម្មកសិកម្ម ចំនួន១៥ នៅក្នុងខ្សែច្រវាក់តម្លៃចំនួន៤ រួមមាន បន្លែ សាច់និងស៊ុត ផ្សិតនិងសិប្បកម្ម។

គោលការណ៍ណែនាំនេះមានបំណង៖

១. បង្កើតឲ្យមានបរិយាកាសអំណោយផលសម្រាប់ ការផ្តល់សេវាផ្សព្វផ្សាយឆ្លើយតបទៅនឹងតម្រូវការទីផ្សារប្រកបដោយប្រសិទ្ធិភាព។
២. រួមចំណែកដល់ផលិតកម្មរបស់កសិករខ្នាតតូច តម្លៃនៃការលក់ផលិតផលនិងកំណើនប្រាក់ចំណេញ។
៣. ប្រើប្រាស់វិធីសាស្ត្រធុរកិច្ចដើម្បីកែលម្អជីវភាពរស់នៅរបស់កសិករតូចតាច តាមរយៈការបង្កើនដើមទុនធនធានមនុស្ស សង្គមកិច្ច រូបវ័ន្ត ហិរញ្ញវត្ថុនិងបរិស្ថាន។

គោលការណ៍ណែនាំនេះត្រូវបានបង្កើតឡើងផ្អែកតាមការសន្មត់ដូចខាងក្រោម៖

១. ការផ្សព្វផ្សាយគឺកាន់តែមានប្រសិទ្ធភាព នៅពេលដែលហានិភ័យទីផ្សារសម្រាប់អ្នកផលិតត្រូវបានកាត់បន្ថយ។
២. ផលិតកម្មកើនឡើង ខណៈពេលដែលការផ្តល់សេវាផ្សព្វផ្សាយនិងបច្ចេកទេសដែលផ្តល់ជូននៅក្នុងបណ្តុំអាជីវកម្មកសិកម្ម ត្រូវបានចរចានិងឯកភាពដោយឈ្មួញលក់សម្ភារៈនិងធាតុចូលកសិកម្ម ជាមួយអ្នកទិញ។ សេវាបច្ចេកទេស និងការផ្សព្វផ្សាយឆ្លើយតបទៅនិងតម្រូវការទីផ្សារ គួរតែអាចបង្កើននូវលទ្ធភាពទទួលយកនូវបច្ចេកទេស និងបច្ចេកវិជ្ជាថ្មីទៅអនុវត្តប្រកបដោយប្រសិទ្ធភាព និងទទួលបានផលចំណេញពីការវិនិយោគភ្លាមៗផងដែរ។
៣. ចំណូលពីការលក់ មិនមែនកើនឡើងដោយសារតែការលក់ផលិតផលក្នុងបរិមាណច្រើននោះទេ ប៉ុន្តែដោយសារកំណើនតម្លៃផលិតផលដែលបានលក់នោះ ផងដែរដូចជាៈ បន្លែមានតម្លៃខ្ពស់ដោយសារមានតម្រូវការច្រើនពីអ្នកទិញ កែលម្អនិងបង្កើនគុណភាពនៃផលិតផលសិប្បកម្ម បង្កើនគុណភាពផ្សិតនិងសាច់មាន់ឱ្យកាន់តែប្រសើរឡើង។ អ្នកទិញអាចផ្តល់តម្លៃបន្ថែមបាន ក្រោយពេលចចារគ្នានិងកំណត់ចំណុចប្រមូលផ្តុំផលិតផល ដែលអាចកាត់បន្ថយចំណាយប្រតិបត្តិការផ្សេងៗ។
៤. វិធីសាស្ត្របណ្តុំអាជីវកម្មកសិកម្ម អាចបង្កើនប្រាក់ចំណេញនិងបន្ថយហានិភ័យបានច្រើន (ទាំងហានិភ័យក្នុងការផលិត និងទីផ្សារ) ។ តាមរយៈការសាកល្បងក្រោមគម្រោង PADEE លើកសិករដែលទទួលយក

បច្ចេកវិទ្យាថ្មីទៅអនុវត្ត និងមានកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនលក់ធាតុចូល និងទទួលទិញផលិតកសិកម្ម បង្ហាញថាការវិនិយោគបែបនេះមានភាពពាក់ព័ន្ធនិងទទួលបានផលចំណេញ។ បណ្តុំអាជីវកម្មកសិកម្ម ផ្តល់ដល់តួអង្គក្នុងស្រុកទាំងអស់ បរិយាកាសអំណោយផល ក្នុងការបង្កើនការជឿទុកចិត្ត កិច្ចសហការ និងការវិនិយោគរួមគ្នាដើម្បីបង្កើនផលិតភាពនិងការអភិវឌ្ឍអាជីវកម្ម។

## វិធីសាស្ត្ររួម

**ច្រវាក់តម្លៃ** គឺជាសំណុំនៃការផ្សារភ្ជាប់គ្នារវាងតួអង្គដែលស្វែងរកការគាំទ្រគ្នាទៅវិញទៅមកយ៉ាងសកម្ម ដែលអាចបង្កើនប្រសិទ្ធភាព និងការប្រកួតប្រជែង។ ពួកគេចំណាយពេលវេលា កិច្ចខំប្រឹងប្រែង និងថវិកាដើម្បីកសាងទំនាក់ទំនងជាមួយអ្នកតួអង្គផ្សេងទៀត ដើម្បីសម្រេចបានគោលដៅរួម គឺបំពេញតម្រូវការរបស់អតិថិជន ដែលចុងក្រោយគឺពួកគេអាចសហការគ្នាដើម្បីបង្កើនប្រាក់ចំណេញរបស់ខ្លួនបាន។

**តួអង្គសំខាន់ៗ** នៅក្នុងខ្សែច្រវាក់តម្លៃ រួមមានអ្នកពាក់ព័ន្ធក្នុងការផលិត ការកែច្នៃ ការជួញដូរ ឬប្រើប្រាស់ផលិតផលកសិកម្មជាក់លាក់ណាមួយ។ ទាំងនេះរួមមានតួអង្គដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការលក់ដូរ ក្នុងច្រវាក់តម្លៃ (អ្នកផលិត ឈ្មួញ អ្នកលក់រាយ និងអ្នកប្រើប្រាស់) និងតួអង្គមិនផ្ទាល់ដែលផ្តល់សេវាគាំទ្រផ្នែកហិរញ្ញវត្ថុឬមិនមែនហិរញ្ញវត្ថុ ដូចជាធនាគារ និងស្ថាប័នឥណទាន អ្នកផ្តល់សេវាអាជីវកម្ម រដ្ឋាភិបាល អ្នកស្រាវជ្រាវនិងអ្នកផ្សព្វផ្សាយកសិកម្ម។

គេអាចនិយាយម៉្យាងទៀតបានថា នៅក្នុងប្រព័ន្ធខ្សែច្រវាក់តម្លៃ មានតួអង្គចំនួនបី : **តួអង្គខ្សែច្រវាក់ផលិតកម្ម** (អ្នកលក់ធាតុចូលកសិកម្ម អ្នកផលិត អ្នកកែច្នៃ អ្នកផ្សព្វផ្សាយ ... ) **អ្នកសម្របសម្រួលទីផ្សារ** (អ្នកប្រមូលទិញ ឈ្មួញកណ្តាល អ្នកលក់ដុំ អ្នកលក់រាយ អ្នកចែកចាយ អ្នកនាំចេញ ... ) និង **អ្នកគាំទ្រប្រព័ន្ធបរិស្ថាន** ដែលផ្តល់សេវាហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ រួមទាំងការអភិវឌ្ឍជំនាញ និងចំណេះដឹងពីទីផ្សារ។



យុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃ រួមបញ្ចូលនៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ នូវអន្តរាគមន៍បីប្រភេទផ្សេងគ្នា:

១. **យុទ្ធសាស្ត្រផលិតកម្ម**: តើត្រូវធ្វើដូចម្តេចដើម្បីផលិតទំនិញ/ផលិតផលមានទាំងគុណភាព និងបរិមាណបំពេញតាមតម្រូវការ ក្នុងពេលវេលាសមស្រប?

២. **យុទ្ធសាស្ត្រទីផ្សារ**: តើត្រូវប្រមូលទំនិញ/ផលិតផលដែលផលិតបានទាន់ពេលវេលាបែបណា ដើម្បីផ្គត់ផ្គង់ដល់អតិថិជន នៅពេលដែលមានការប្រកួតប្រជែង?

៣. **យុទ្ធសាស្ត្រគាំទ្រ**: តើត្រូវផ្តល់សេវាអភិវឌ្ឍន៍ជំនាញ ព័ត៌មាននិងចំណេះដឹង ហិរញ្ញវត្ថុ ការសម្របសម្រួលកិច្ចសន្ទនា និងជម្រុញកិច្ចសហប្រតិបត្តិការរវាងអ្នកដើរតួអង្គពាក់ព័ន្ធដើម្បីពន្លឿនការអភិវឌ្ឍ និងជម្រុញទំនាក់ទំនងអាជីវកម្មប្រកបដោយប្រសិទ្ធភាព?

ដើម្បីធ្វើឱ្យយុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃនេះជោគជ័យ ជាចាំបាច់ណាស់ដែលតួអង្គទាំងអស់នៃប្រព័ន្ធខ្សែច្រវាក់តម្លៃរក្សានៅការជជែកគ្នាពិភាក្សាជាមួយគ្នាទៅវិញទៅមកជាប់ជាប្រចាំ។




**បណ្តុំអ្នកផលិត** គឺជាការប្រមូលផ្តុំអ្នកពាក់ព័ន្ធដែលមានទំនាក់ទំនងជាមួយគ្នាក្នុងភូមិសាស្ត្រណាមួយ ដើម្បីទាញប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលក្នុងចំណោមកិច្ចការរបស់ពួកគេឱ្យបានច្រើនបំផុត តាមរយៈកិច្ចសហការនិងទទួលបានលទ្ធផលគាប់ល្អប្រសើរជាងមុន។ ចងក្រងបណ្តុំអ្នកផលិតតាមភូមិសាស្ត្រ តួអង្គសំខាន់ៗនៅតាមខ្សែច្រវាក់តម្លៃនៅក្នុងតំបន់តែមួយ។ តួអង្គសំខាន់រួមមាន អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម កសិករ អ្នកទិញ អ្នកផ្តល់សេវាកម្ម និងភ្នាក់ងាររដ្ឋាភិបាលដែលបានចូលរួមពិភាក្សាគ្នាលើបញ្ហាដែលបានរកឃើញនៅក្នុងកិច្ចប្រជុំភាគីអ្នកពាក់ព័ន្ធ ហើយបង្កើតផែនការសកម្មភាពរួមគ្នា ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

បណ្តុំអ្នកផលិតនេះ អាចត្រូវបានមើលឃើញថាជា "សមាគមន៍អ្នកពាក់ព័ន្ធ" ដែលជាឧបករណ៍មួយដើម្បី:

១. ពន្លឿនកំណើននៅក្នុងខ្សែច្រវាក់ផលិតកម្មនូវច្រវាក់ទំនិញដែលបានជ្រើសរើស។

២. ជម្រុញឱ្យកសិករខ្នាតតូចចូលរួមបានយូរអង្វែងក្នុងខ្សែច្រវាក់តម្លៃដែលបានជ្រើសរើស។

៣. ធ្វើឱ្យខ្សែច្រវាក់ផលិតកម្មបានប្រសើរឡើង ទាំងការប្រកួតប្រជែង ស្មើភាព ការសម្របសម្រួល និងការជឿទុកចិត្ត។

៤. បង្កើនភាពជាដៃគូរវាងវិស័យសាធារណៈ ផ្នែកឯកជននិងស៊ីវិល។

គោលបំណងនៃការរៀបចំបណ្តុំនីមួយៗនេះ សំដៅពន្លឿនប្រតិបត្តិការនិងកាត់បន្ថយការចំណាយ ជម្រុញកិច្ចសហប្រតិបត្តិការអាជីវកម្មនៅតាមខ្សែច្រវាក់ និងបង្កើតភាពជាដៃគូរវាងអ្នកផ្តល់សេវាកម្មនិង ស្ថាប័នរដ្ឋាភិបាល។ កិច្ចសន្ទនា អន្តរកម្មនិងការគាំទ្រ នឹងមានផ្តល់ជូនតាមរយៈកិច្ចប្រជុំភាគីពាក់ព័ន្ធ ។




## ដំណើរការ

ដំណើរការនេះ ត្រូវអនុវត្តតាម ៧ជំហានដូចតទៅ៖

១. ការចុះសិក្សាតម្រូវការទីផ្សារ និងការវិភាគ។

២. ការប្រជុំ និងពិភាក្សាជាមួយតួអង្គសំខាន់ក្នុងខ្សែច្រវាក់តម្លៃ។

៣. ការបង្កើតជាបណ្តុំ និងរចនាសម្ព័ន្ធ។

៤. រៀបចំវេទិការវាងភាគីពាក់ព័ន្ធ (បណ្តុំអ្នកផលិត អ្នកប្រមូលទិញ អ្នកលក់សម្ភារៈកសិកម្ម និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ)។

៥. រៀបចំកិច្ចសន្យារវាង អ្នកផលិត និងឈ្មួញ។

៦. គាំទ្រការអនុវត្តន៍បណ្តុំ (មានកញ្ចប់ថវិកាជួយដល់យន្តការនេះ)។

៧. តាមដាន និងវាយតម្លៃ។

### ១. ការចុះសិក្សាតម្រូវការទីផ្សារ និងការវិភាគ

**គោលបំណង**

- កំណត់តួអង្គសំខាន់ៗនៃខ្សែច្រវាក់ផលិតកម្ម: តួអង្គនៃខ្សែច្រវាក់ផលិតកម្ម (អ្នកលក់ធាតុចូលកសិកម្ម អ្នកផលិត អ្នកកែច្នៃ អ្នកផ្សព្វផ្សាយ ... ) តួអង្គនៃខ្សែច្រវាក់ទីផ្សារ (អ្នកប្រមូលទិញ ឈ្មួញកណ្តាល

អ្នកលក់ដុំ អ្នកលក់រាយ អ្នកចែកចាយ អ្នកនាំចេញ ... ) និងតួអង្គគាំទ្រប្រព័ន្ធអេកូឡូស៊ី (ដែលផ្តល់សេវាកម្មហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ រួមទាំងការអភិវឌ្ឍជំនាញ និងចំណេះដឹងទីផ្សារ)

- សម្រាំងតួអង្គសំខាន់ៗ និងបណ្តុំដែលមានសក្តានុពល
- កំណត់ឧបសគ្គនិងឱកាស ហើយចង្អុលបង្ហាញពីបទអន្តរាគមន៍ដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍខ្សែច្រវាក់តម្លៃ។

**លទ្ធផលរំពឹងទុក**

- មន្ត្រីនិងបុគ្គលិកពាក់ព័ន្ធបានយល់អំពីនីតិវិធីឬវិធីសាស្ត្រនៃការសិក្សាទីផ្សារ និងការប្រមូលទិន្នន័យ
- បញ្ជីឈ្មោះតួអង្គក្នុងខ្សែច្រវាក់តម្លៃ
- បញ្ជីសម្រាំងបណ្តុំដែលមានសក្តានុពល និងតួអង្គ
- តារាងបរិយាយពីឧបសគ្គ ឱកាស និងកិច្ចអន្តរាគមន៍សាធារណៈដែលមានសក្តានុពលសម្រាប់បណ្តុំនីមួយៗ។

**សង្ខេបពីដំណើរការសិក្សាតម្រូវការទីផ្សារ**

1. ផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីបង្គោល
2. ការកំណត់តួអង្គសំខាន់ៗយ៉ាងឆាប់រហ័ស
3. កំណត់ផលិតផល អ្នកប្រមូលទិញឬដៃគូរសម្រាប់ទីផ្សារ

## ១.១ ផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីបង្គោល

**គោលបំណង**

ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការចុះសិក្សាតម្រូវការទីផ្សារ ដល់មន្ត្រីកសិកម្មខេត្ត ស្រុក។

**លទ្ធផលរំពឹងទុក**

មន្ត្រីមានចំណេះដឹងពីដំណើរការ និងវិធីសាស្ត្រសិក្សាតម្រូវការទីផ្សារ ។

ក្រុមការងារនៃអគ្គនាយកដ្ឋានកសិកម្ម នឹងចុះតាមខេត្តគោលដៅដើម្បីពន្យល់ពីគោលបំណង និងវិធីសាស្ត្រនៃការកំណត់តួអង្គសំខាន់ៗយ៉ាងរហ័ស និងការព្រមព្រៀងសហការដោយផ្តល់បុគ្គលិកចូលរួម ពេលវេលានិងបញ្ហាភស្តុភារ។

## ១.២ ការកំណត់ព័ត៌មានរហ័ស

ការកំណត់ព័ត៌មានរហ័ស នឹងត្រូវធ្វើឡើងលើទំនិញ/ផលិតផលពាក់ព័ន្ធទាំងអស់នៅក្នុងឃុំ ស្រុកនិងខេត្តគោលដៅ។

- **ការប្រមូលទិន្នន័យ (សម្ភាសន៍)**:នៅតាមស្រុក និងខេត្តនីមួយៗ មន្ត្រីកសិកម្មខេត្តនិងស្រុកត្រូវ៖ ១.រៀបចំបញ្ជីអ្នកដែលត្រូវសម្ភាសន៍ (អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកផលិត និងអ្នកបោះដុំ) ២. សម្ភាសន៍អ្នកផ្គត់ផ្គង់ធាតុចូល និងឈ្មួញទិញដុំ (ទម្រង់ ១-២) ៣. ពិភាក្សាជាមួយក្រុមអ្នកផលិតដែលមានសក្តានុពល និងកំណត់តំបន់ដាំដុះ។ សម្រាប់កិច្ចពិភាក្សាជាមួយក្រុមអ្នកផលិត សូមប្រើទម្រង់ ៣ ។ សម្រាប់ការកំណត់តំបន់ដាំដុះ សូមប្រើ GPS និង/ឬកម្មវិធីដូចជា Agribuddy ។
- **ការបញ្ចូលទិន្នន័យ**: មន្ត្រីទទួលបន្ទុកផ្នែកទីផ្សារនៅថ្នាក់ខេត្តនិងមន្ត្រីកសិកម្មស្រុក ទទួលបន្ទុកបញ្ចូលទិន្នន័យនិងកំណត់តំបន់ដាំដុះដោយប្រើប្រាស់ទម្រង់ ៤ ។

### ១.៣ កំណត់ផលិតផល ឈ្មួញអ្នកទិញឬដៃគូទីផ្សារ

ក្រោយពេលបញ្ចប់ការកំណត់តំបន់ដាំដុះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF) នឹងផ្តល់បញ្ជីសម្រាំងឈ្មោះបណ្តុំអ្នកផលិតដែលមានសក្តានុពល (កន្លែងប្រមូលផ្តុំ) និងសមាជិកក្រុមសម្រាប់ផលិតផលជាក់លាក់ (ទម្រង់៥)។

**បណ្តុំអ្នកផលិត** គឺជាការប្រមូលផ្តុំក្នុងភូមិសាស្ត្រមួយ នៅអ្នកផលិត អាជីវកម្ម អ្នកផ្គត់ផ្គង់ និងស្ថាប័នដែលពាក់ព័ន្ធ ដែលបង្កើតឱ្យមានការប្រមូលផ្តុំដោយផ្ទាល់និងដោយប្រយោល តាមរយៈទំនាក់ទំនងទីផ្សារ។

វិធីសាស្ត្រចងក្រងបណ្តុំអ្នកផលិត គឺចងក្រងក្រុមតួអង្គពាក់ព័ន្ធសំខាន់ៗនៅក្នុងខ្សែច្រវាក់ផលិតកម្មក្នុងតំបន់តែមួយ។ តួអង្គសំខាន់រួមមាន អ្នកផ្គត់ផ្គង់ធាតុចូល កសិករ អ្នកទិញ អ្នកផ្តល់សេវាកម្ម និងភ្នាក់ងាររដ្ឋាភិបាលដែលបានចូលរួមពិភាក្សានិងគិតគូរពីបញ្ហាដែលកើតមានឡើងនានា តាមរយៈកិច្ចប្រជុំភាគីពាក់ព័ន្ធ ហើយបង្កើតផែនការសកម្មភាពរួមដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ការចងក្រងជាបណ្តុំនេះ ជាជំហានដំបូងមួយក្នុងដំណើរឆ្ពោះទៅរកការបង្កើតជាសហគមន៍កសិកម្ម។

អត្ថប្រយោជន៍ជាសក្តានុពលសម្រាប់តួអង្គសំខាន់ៗនៅក្នុងខ្សែច្រវាក់តម្លៃនៃបណ្តុំអ្នកផលិតនេះ រួមមាន:
**អត្ថប្រយោជន៍ដល់កសិករ:** (ការបារម្ភពាក់ព័ន្ធទៅនឹងតម្លៃ ផែនការផលិតកម្ម និងធាតុចូល/ពេលវេលាដែលមាន):

- ទីផ្សារប្រមូលផ្តុំនិងលទ្ធភាពចូលកាន់ទីផ្សារកាន់តែប្រសើរ ក៏ដូចជាអំណាចក្នុងការចរចាតម្លៃកាន់តែប្រសើរ
- ការកើនឡើងប្រាក់ចំណូល ដោយសារផលិតផលមានតម្លៃខ្ពស់និងកំណើនផលិតកម្ម
- ចំណងទាក់ទងកាន់តែល្អប្រសើរជាងមុនរវាងអ្នកផលិតនិងតួអង្គផ្សេងទៀត
- អន្តរកម្មជាមួយអ្នកទិញកាន់តែល្អឡើង ដោយសារតែទំនាក់ទំនងល្អនិងការជឿទុកចិត្តកាន់តែប្រសើរឡើង
- ចំណាយផលិតកម្មទាបដោយសារតែទំនាក់ទំនងល្អប្រសើរជាមួយអ្នកផ្គត់ផ្គង់ធាតុចូល
- ការអភិវឌ្ឍអាជីវកម្មក្រុមរយៈពេលវែង។

**អត្ថប្រយោជន៍ចំពោះអ្នកទិញ:** (ការបារម្ភអំពីបរិមាណ គុណភាព និងភាពជឿជាក់បាននៃការផ្គត់ផ្គង់)

- ការទទួលបានការផ្គត់ផ្គង់ផលិតផលក្នុងបរិមាណច្រើន (បរិមាណ គុណភាព និងភាពទៀងទាត់)
- បង្កើនទំនុកចិត្តរវាងអ្នកផ្គត់ផ្គង់និងសមាជិកក្នុងបណ្តុំអ្នកផលិតផ្សេងទៀត
- ការធានាបានការផ្គត់ផ្គង់ជាទៀងទាត់នូវផលិតផលក្នុងបរិមាណសមស្រប មានគុណភាពក្នុងតម្លៃសមរម្យ
- ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនៃការឆ្លើយតប និងការចង់បានរបស់ទីផ្សារ ដើម្បីឆ្លើយតបឲ្យបានរហ័សទៅនឹងតម្រូវការទីផ្សារ។

## ២. ការប្រជុំ និងពិភាក្សាជាមួយតួអង្គនៅក្នុងខ្សែច្រវាក់តម្លៃ

**គោលបំណង**: បង្ហាញលទ្ធផលនៃការសិក្សាវាយតម្លៃតម្រូវការទីផ្សារ បង្ហាញនិងបញ្ជាក់ពីផលប្រយោជន៍នៃការបង្កើតបណ្តុំផលិត។

**លទ្ធផលរំពឹងទុក: ការធ្វើបច្ចុប្បន្នភាពបញ្ជីសម្រាំងបណ្តុំអ្នកផលិត។** តាមរយៈបញ្ជីសម្រាំងបណ្តុំអ្នកផលិតដែលមានសក្តានុពល មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងរៀបចំកិច្ចប្រជុំជាមួយតួអង្គនៅក្នុងខ្សែច្រវាក់តម្លៃនេះ ដើម្បីផ្តល់សុពលភាពលើរបាយការណ៍ និងស្វែងយល់ពីចំណាប់អារម្មណ៍របស់តួអង្គទាំងនេះក្នុងការធ្វើការរួមគ្នាដោយមានការគាំទ្រពី មន្ទីរកសិកម្ម ។ កិច្ចប្រជុំដាច់ដោយឡែកចំនួនពីរ នឹងត្រូវរៀបចំឡើងដោយ មន្ទីរកសិកម្ម: (១) កិច្ចប្រជុំជាមួយអ្នកលក់ធាតុចូល និងអ្នកបោះដុំ (២) កិច្ចប្រជុំជាមួយអ្នកផលិតដែលមានសក្តានុពល។

កិច្ចប្រជុំនេះនឹងផ្តោតលើ:

- បង្ហាញបញ្ជីសម្រាំងបណ្តុំអ្នកផលិត បញ្ហានិងដំណោះស្រាយដែលអាចអនុវត្តបាន
- បង្ហាញពីលទ្ធភាពដែល មន្ទីរកសិកម្ម អាចគាំទ្រដល់បណ្តុំអ្នកផលិតនិងតួអង្គក្នុងខ្សែច្រវាក់តម្លៃ
- បញ្ជាក់ពីចំណាប់អារម្មណ៍របស់តួអង្គក្នុងការចូលរួមក្នុងបណ្តុំអ្នកផលិត។

ក្រោយកិច្ចប្រជុំនេះ មន្ទីរកសិកម្ម ត្រូវធ្វើបច្ចុប្បន្នភាពតារាងបញ្ជីសម្រាំង ( ទម្រង់ ៥ ) ។

## ៣. ការបង្កើតជាបណ្តុំផលិត ( Clusters ) និងរចនាសម្ព័ន្ធ

**គោលបំណង**

រៀបចំបណ្តុំផលិត អ្នកទិញ និងផែនការផ្គត់ផ្គង់ទីផ្សារ ។

**លទ្ធផលរំពឹងទុក**

ក្រុមអ្នកផលិតស្របតាមតម្រូវការទីផ្សារ (Producer Market Linked-PML) ត្រូវបានបង្កើតឡើង។

មន្ត្រីកសិកម្មស្រុកនឹងរៀបចំកិច្ចប្រជុំបណ្តុំអ្នកផលិតក្នុងខ្សែច្រវាក់តម្លៃ ដោយជ្រើសរើសចេញពីបញ្ជីសម្រាំង។ តួអង្គសំខាន់ៗនៅក្នុងខ្សែច្រវាក់តម្លៃ រួមមានអ្នកផ្គត់ផ្គង់ធាតុចូល អ្នកផលិតក្នុងស្រុក និងអ្នកបោះដុំ ពិនិត្យរួមគ្នាលើបញ្ហារាំងស្ទះនៅក្នុងខ្សែច្រវាក់តម្លៃលើទំនិញជាក់លាក់ និងស្វែងរកដំណោះស្រាយដែលមានសក្តានុពល។

ក្រោយកិច្ចប្រជុំក្រុមអ្នកផលិតស្របតាមតម្រូវការទីផ្សារ ( PML ) ត្រូវបានបង្កើតឡើងក្នុងចំណោមអ្នកផលិតទាំងនោះ។ ការជ្រើសរើសសមាជិកក្រុមអ្នកផលិតស្របតាមតម្រូវការទីផ្សារ ( Market Producer Linked-MPL ) គឺសម្រាប់តែកសិករណាដែលមានឆន្ទៈក្នុងការអនុវត្តកសិកម្មល្អ ( GAP ) និងផលិតសម្រាប់លក់។ ការងាររបស់ក្រុមអ្នកផលិតស្របតាមតម្រូវការទីផ្សារ ដំបូងឡើងចាប់ផ្តើមពីការប្រមូលផ្តុំផលិតផលតាមគ្រួសារ និងការលក់ពីសមាជិកម្នាក់ៗ ក្រោយមកឈានទៅរកការបង្កើតជាសហគមន៍កសិកម្ម នៅពេលដែលត្រៀមលក្ខណៈបានរួចរាល់។

ការបង្កើត ក្រុមអ្នកផលិតស្របតាមតម្រូវការទីផ្សារ រួមមានការបោះឆ្នោតជ្រើសរើសប្រធានក្រុម ការបង្កើតបទបញ្ជាផ្ទៃក្នុងដែលងាយស្រួល ការកំណត់ទីតាំងប្រមូលផ្តុំ កំណត់ប្រព័ន្ធកត់ត្រានិងទូទាត់ថវិកា។

## ៤. រៀបចំវេទិកាពហុភាគីពាក់ព័ន្ធ ( MSP-Multi Stakeholder Platform Meeting )

**គោលបំណង**

បង្កើតផែនការអាជីវកម្ម និងយុទ្ធសាស្រ្តអភិវឌ្ឍន៍ទីផ្សារ ។

**លទ្ធផលរំពឹងទុក**

ការជ្រើសរើសតួអង្គក្នុងខ្សែច្រវាក់តម្លៃដើម្បីបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ក្រោយពេលបង្កើត ក្រុមអ្នកផលិតស្របតាមតម្រូវការទីផ្សារ មន្ត្រីកសិកម្មស្រុកនឹងរៀបចំកិច្ចប្រជុំរវាងក្រុម ( PML ) នីមួយៗជាមួយអ្នកផ្គត់ផ្គង់ធាតុចូលនិងអ្នកបោះដុំ ដើម្បីពិនិត្យលើលទ្ធភាពនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា។ កិច្ចប្រជុំនេះ នឹងពិភាក្សាលើ:

ជំហាន ទី ១: បទបង្ហាញពីមន្ត្រីការិយាល័យកសិកម្មស្រុក ( DoA ) លើគោលការណ៍នៃការគាំទ្រជាសាធារណៈ
ជំហានទី ២: បទបង្ហាញពីអ្នកបោះដុំ អំពីមុខទំនិញដែលត្រូវទិញ និងបរិមាណ។ ល។
ជំហានទី ៣: បទបង្ហាញពីក្រុម ក្រុមអ្នកផលិតស្របតាមតម្រូវការទីផ្សារ

ជំហានទី ៤: បទបង្ហាញពីអ្នកផ្គត់ផ្គង់ធាតុចូល
ជំហានទី ៥: បំពេញទម្រង់ ៦ ។

## ៥. រៀបចំកិច្ចសន្យារវាង អ្នកផលិត និងឈ្មួញ

**គោលបំណង**

ភ្ជាប់ទំនាក់ទំនងរវាងតួអង្គក្នុងខ្សែច្រវាក់តម្លៃ

**លទ្ធផលរំពឹងទុក**

ផលិតកម្មកសិកម្មតាមកិច្ចសន្យា ត្រូវបានចុះហត្ថលេខា។

ក្រោយបំពេញទម្រង់ ៦ ចប់ មន្ត្រីកសិកម្មស្រុក ត្រូវសម្របសម្រួលការពិភាក្សារវាងអ្នកបោះដុំដែលមានការប្តេជ្ញាចិត្ត ក្រុម ក្រុមអ្នកផលិតស្របតាមតម្រូវការទីផ្សារ និងអ្នកលក់ធាតុចូល - តាមក្រុមនីមួយៗដាច់ដោយឡែកដើម្បីបង្កើតកិច្ចសន្យា។ កិច្ចសន្យាជាមួយអ្នកបោះដុំ ត្រូវធ្វើមុន បន្ទាប់មកគឺកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់ធាតុចូល។

កិច្ចសន្យានេះ ត្រូវគ្របដណ្តប់លើកិច្ចប្រតិបត្តិការ និងការគាំទ្រផ្នែផ្សព្វផ្សាយ។ សម្រាប់អ្នកទិញ ការគាំទ្រលើការងារផ្សព្វផ្សាយ គួរផ្តោតលើលក្ខណៈលម្អិត ចំណាត់ថ្នាក់ កាលវិភាគ បរិមាណនិងលទ្ធភាពការងារគ្រប់គ្រងក្រោយពេលប្រមូលផល និងសេវាប្រមូលផ្តុំដែលត្រូវផ្តល់ដល់សមាជិកដែលមានចំណាប់អារម្មណ៍ (MIG) ។ សម្រាប់អ្នកផ្គត់ផ្គង់ធាតុចូល ត្រូវផ្តល់ដំបូន្មានពីបច្ចេកទេសផលិត និងសេវាក្រោយពេលលក់ ដែលត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យា។

កិច្ចសន្យាជាមួយអ្នកប្រមូលទិញដុំ ត្រូវគ្របដណ្តប់យ៉ាងហោចណាស់ចំណុចមួយចំនួនដូចតទៅ: (i) យន្តការកំណត់តម្លៃ (ii) លក្ខណៈលម្អិតរបស់ទំនិញ (iii) ចំណាត់ថ្នាក់គុណភាពនិងការវេចខ្ចប់ (iv) កាលវិភាគនៃការដឹកជញ្ជូន/ប្រគល់ទំនិញ (v) របៀបទូទាត់សង និង (vi) ការអនុវត្តន៍តម្រូវការអប្បបរមានៃការអនុវត្តកសិកម្មល្អ (GAP) ។ ផ្នែកសេវាកម្ម រួមបញ្ចូលការត្រួតពិនិត្យគុណភាព ការបណ្តុះបណ្តាលនិងការប្រមូលទំនិញ។ កិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់ធាតុចូល ត្រូវគ្របដណ្តប់យ៉ាងហោចណាស់លើចំណុចតទៅនេះ: (i) ការវេចខ្ចប់ធាតុចូលកសិកម្ម (ii) ការបណ្តុះបណ្តាល និង (iii) សេវាកម្មក្រោយពេលលក់។

## ៦. គាំទ្រការអនុវត្តបណ្តុំ (មានកញ្ចប់ថវិកាជួយដល់យន្តការនេះ)

**គោលបំណង**

ដើម្បីមានការទុកចិត្តគ្នារវាង បណ្តុំអ្នកផលិត អ្នកប្រមូលទិញ និងការរក្សាតម្លៃកសិផលបានល្អ។

**លទ្ធផលរំពឹងទុក**

អនុវត្តកិច្ចសន្យាឱ្យបានរលូន។

ក្រោយពេលមានកិច្ចសន្យា មន្ត្រីកសិកម្មស្រុកនឹងរៀបចំកិច្ចប្រជុំជាមួយតួអង្គពាក់ព័ន្ធទាំងអស់ នៅក្នុងខ្សែច្រវាក់តម្លៃវេទិកាពហុភាគីពាក់ព័ន្ធ (MSP) ដើម្បីពិនិត្យមើលរួមគ្នាបញ្ហារាំងស្ទះក្នុងការអនុវត្តកិច្ចសន្យា និងស្វែងរកដំណោះស្រាយដែលមានសក្តានុពល។

**លទ្ធភាពនៃការគាំទ្រពីផ្នែករដ្ឋ រួមមាន៖**

**ក. ពង្រឹងសមត្ថភាពកសិករ**

- ការអនុវត្តកសិកម្មល្អ (GAP)

- ផ្ទះសំណាញ់
- សមត្ថភាពទីផ្សារ
- ការទាមទារជាក់ស្តែងដែលបានលើកឡើងនៅក្នុងវេទិកាពហុភាគីពាក់ព័ន្ធ ។

**ខ. គាំទ្រវិនិយោគសាធារណៈ ផ្តល់ជូន អតិបរមា ៩៥% នៃទុនសរុប**

- ផ្សារប្រមូលទិញដុំ
- កន្លែងប្រមូលផ្តុំផលិតផលកសិកម្ម (កន្លែងរក្សាផលិតផលដែលមានសភាពត្រជាក់ ឧបករណ៍សម្រាប់ធ្វើតេស្ត ស្អាត ម៉ាស៊ីនវេចខ្ចប់)
- ហេដ្ឋារចនាសម្ព័ន្ធផលិតនិងទីផ្សារ (ផ្លូវ ប្រឡាយទឹក ស្រះ អណ្តូង អាងស្តុក ស្ទូឡា...)
- សត្តឃាតដ្ឋានបក្សី។

**គ. មូលនិធិសម្រាប់គំនិតផ្តួចផ្តើមថ្មី**

ដើមទុនសរុបចំនួន ២០% ត្រូវបានផ្តល់ជូន។

**ឃ. ផ្សារភ្ជាប់បណ្តុំអាជីវកម្មទៅនឹងមីក្រូហិរញ្ញវត្ថុ**

**ង. ផ្សព្វផ្សាយផលិតផលរបស់បណ្តុំអាជីវកម្មកសិកម្ម**

ពិព័ណ៌ផលិតផលកសិកម្មប្រចាំឆ្នាំ ។

**ច.ការគាំទ្រនិងតាមដាន។**

## ៧. តាមដាន និងវាយតម្លៃ

**គោលបំណង**

ជំរុញឲ្យបណ្តុំអាជីវកម្មដំណើរការមានប្រសិទ្ធភាព ។

### ៧.១ តាមដាន និងវាយតម្លៃលទ្ធផលការផ្គត់ផ្គង់ទីផ្សារ

- តាមដានការផលិតរបស់បណ្តុំ
- សមាជិកបណ្តុំត្រូវមានសៀវភៅកត់ត្រាៈ បរិមាណលក់ (ក្រុម) ការទទួលយកបច្ចេកទេស(ក្រុម) ប្រាក់ចំណូល ចំណាយ និងប្រាក់ចំណេញ(សមាជិក)
- បញ្ចូលក្នុងប្រព័ន្ធMIS ។

### ៧.២ តាមដាន វាយតម្លៃបណ្តុំ និងការគាំទ្របន្ត

- មន្ត្រីបច្ចេកទេសកសិកម្មថ្នាក់ខេត្ត និងថ្នាក់ស្រុកត្រូវធ្វើការពិភាក្សាជាមួយបណ្តុំផលិត តើបណ្តុំមានជួបប្រទះបញ្ហាអ្វីខ្លះ តើបណ្តុំផលិតសំណូមពរជួយគាំទ្រអ្វីខ្លះបន្តទៀតក្នុងឆ្នាំទី៣
- កសាងសមត្ថភាព (បច្ចេកទេស GAP ទស្សនៈកិច្ចសិក្សា...) អាស្រ័យតាមតម្រូវការជាក់ស្តែងរបស់បណ្តុំ
- បណ្តុះបណ្តាលពីការទទួលព័ត៌មានទីផ្សារ (សារខ្លីៗតាមទូរស័ព្ទ) ដើម្បីទទួលបានតម្លៃទីផ្សារ និងស្គាល់អ្នកប្រមូលទិញថ្មីទៀត
- បណ្តុះបណ្តាលការទុកដាក់ ដឹកជញ្ជូន និងវេចខ្ចប់ក្រោយពេលប្រមូលផល
- ផែនការផ្គត់ផ្គង់ទីផ្សារ និងការកត់ត្រា/ការគ្រប់គ្រងផែនការជំនួញ
- ការចងក្រងកិច្ចសន្យាជាមួយឈ្មួញកណ្តាល។

## ៨. តួនាទី និងភារកិច្ចរបស់មន្ត្រីជំនាញ

**គោលបំណង**

បែងចែកតួនាទីនិងភារកិច្ចរបស់មន្ត្រីជំនាញ តាមនាយកដ្ឋាន មន្ទីរ ការិយាល័យពាក់ព័ន្ធក្នុងការគាំទ្រដល់សកម្មភាពបណ្តុំផលិតកម្មកសិកម្ម។

**លទ្ធផលរំពឹងទុក**

មន្ត្រីជំនាញ តាមនាយកដ្ឋាន មន្ទីរ ការិយាល័យពាក់ព័ន្ធ យល់ច្បាស់ពីតួនាទី និងភារកិច្ចក្នុងការគាំទ្របណ្តុំផលិតកម្មកសិកម្ម។

### ៨.១ តួនាទី និងភារកិច្ច ក្រសួងពាណិជ្ជកម្ម

- សហការក្នុងការរៀបចំគោលការណ៍ណែនាំ ការផ្សារភ្ជាប់ផលិតផលកសិកម្មឆ្ពោះទៅទីផ្សារ
- សហការក្នុងការគាំទ្របច្ចេកទេស និងផ្តល់ថវិកាក្នុងការអនុវត្តបណ្តុំអាជីវកម្មកសិកម្ម
- សហការតាមដាន និងផ្តល់ការវាយតម្លៃក្នុងការអនុវត្តបណ្តុំអាជីវកម្មកសិកម្ម។

### ៨.២ តួនាទី និងភារកិច្ច នាយកដ្ឋានផែនការនិងស្ថិតិ/ការិយាល័យទីផ្សារកសិកម្ម

- សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រៀបចំគោលការណ៍ណែនាំ និងផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីជំនាញតាមខេត្តសម្រាប់ជួយគាំទ្រក្រុមផលិត
- ចុះពិនិត្យការប្រមូលទិន្នន័យ និងជួយវិភាគទិន្នន័យឬផ្តល់យោបល់
- ចូលរួមប្រជុំ ពិនិត្យនិងផ្តល់យោបល់លើលទ្ធផលនៃការប្រមូល និងវិភាគទិន្នន័យ
- ពង្រឹងសមត្ថភាពលើការងារជំនាញដល់មន្ត្រីជំនាញ សហគមន៍ និងបណ្តុំផលិតសម្រាប់ទីផ្សារ
- ចុះតាមដានអំពីដំណើរការរបស់បណ្តុំផលិតសម្រាប់ទីផ្សារ។

### ៨.៣ តួនាទីនិងភារកិច្ចរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម

- សហការជាមួយការិយាល័យទីផ្សារកសិកម្ម ដើម្បីរៀបចំនិងផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីបច្ចេកទេស
- ចូលរួមប្រជុំដើម្បីពិនិត្យឡើងវិញនិងផ្តល់យោបល់លើលទ្ធផលវាយតម្លៃ
- ផ្តល់ការគាំទ្របច្ចេកទេសជាបន្ត
- ចុះតាមដានអំពីដំណើរការរបស់បណ្តុំផលិតសម្រាប់ទីផ្សារ។

### ៨.៤ តួនាទីនិងភារកិច្ចរបស់មន្ត្រីទីផ្សារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ផ្សព្វផ្សាយគោលការណ៍ដល់ភ្នាក់ងារអនុវត្ត ថ្នាក់ស្រុក ឃុំ និងបណ្តុំផលិតសម្រាប់ទីផ្សារ
- ប្រមូលទិន្នន័យ វិភាគ និងបូកសរុបរបាយការណ៍
- ពិនិត្យនិងផ្តល់យោបល់លើ របាយការណ៍លទ្ធផលចុះសិក្សាជាមួយ ថ្នាក់ស្រុក និងឃុំ
- ចូលរួមប្រជុំផ្សព្វផ្សាយជាមួយក្រុមកសិករ និងចងក្រងបណ្តុំផលិតសម្រាប់ទីផ្សារ
- ជួយរៀបចំឯកសារកិច្ចសន្យារវាងបណ្តុំផលិត និងអ្នកប្រមូលទិញ
- ពិនិត្យរាល់សកម្មភាព និងផ្តល់ការគាំទ្រដល់បណ្តុំផលិត
- ពង្រឹងសមត្ថភាពលើការងារជំនាញដល់មន្ត្រីជំនាញថ្នាក់ស្រុក ឃុំ សហគមន៍ និងបណ្តុំផលិត
- តាមដានសកម្មភាពបណ្តុំផលិតសម្រាប់ទីផ្សារ។

**៨.៥ មន្ត្រីបច្ចេកទេសកសិកម្មថ្នាក់ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ**

- សហការជាមួយមន្ត្រីបច្ចេកទេសផ្នែកទីផ្សារថ្នាក់ខេត្ត ក្នុងការកំណត់ទីផ្សារ និងឈ្មួញទិញដុំ ឈ្មួញកណ្តាល អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលត្រូវធ្វើសម្ភាសន៍
- ចុះសម្ភាសន៍តាមទីផ្សារ
- មន្ត្រីថ្នាក់ស្រុកបញ្ចូលទិន្នន័យ និងបញ្ជូនទិន្នន័យដល់មន្ត្រីទីផ្សារថ្នាក់ខេត្ត
- រៀបចំនិងសម្របសម្រួល វេទិការវាងបណ្តុំផលិត និងអ្នកប្រមូលទិញ
- សម្របសម្រួលរៀបចំប្រជុំពិភាក្សាជាមួយក្រុមកសិករ និងបណ្តុំផលិត ដើម្បីរៀបចំផែនការអាជីវកម្ម
- តាមដាន និងផ្តល់ការគាំទ្របច្ចេកទេសដល់បណ្តុំផលិត
- រាយការណ៍លទ្ធផលដែលអនុវត្តន៍បានជូនដល់ថ្នាក់ខេត្ត។

# សំណួរណែនាំសម្រាប់អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម

**១- ព័ត៌មានទូទៅ**

- ឈ្មោះ.............................ភេទ.............លេខទូរស័ព្ទ........................ អ៊ីម៉ែល.....................
- ហៀសប៊ុក.........................................អាស័យដ្ឋាន ភូមិ.................. ឃុំ..............................
ស្រុក.................................... ខេត្ត...................................
- ឈ្មោះតំបន់គោលដៅដែលអ្នកកំពុងប្រតិបត្តិការៈ
  - ភូមិ...........................................................
  - ឃុំ...........................................................
  - ស្រុក.........................................................

**២ - សំណួរណែនាំ**

| | |
|---|---|
| ១ | តើវត្ថុធាតុដើមកសិកម្មសំខាន់ៗអ្វីខ្លះដែលអ្នកកំពុងលក់? |
| ២ | តើក្នុងផលិតផលមួយមុខៗជាក់លាក់ដែលអ្នកកំពុងលក់មានបរិមាណ/ទំហំប៉ុន្មានដែរ? |
| ៣ | តើអតិថិជនធំៗរបស់អ្នកជានរណាខ្លះ? តើពួកគេនៅទីណា? តើអាចប៉ាន់ស្មានពីចំនួនអតិថិជនធំៗបានដែរឬទេ? |
| ៤ | ប្រភពនៃធាតុចូលកសិកម្ម? |
| ៥ | តើសេវាកម្មអ្វីខ្លះដែលអ្នកអាចផ្តល់ដល់អតិថិជនទាំងនេះបាន? |
| ៦ | តើអ្នកលក់យកជាលុយសុទ្ធឬឱ្យជំពាក់? |
| ៧ | តើមានឧបសគ្គអ្វីខ្លះក្នុងការលក់វត្ថុធាតុដើមទាំងនេះ? |
| ៨ | តើមានដំណោះស្រាយអ្វីខ្លះដែលអ្នកចង់លើកឡើងដើម្បីដោះស្រាយបញ្ហា/ឧបសគ្គទាំងនេះ និងអាចមានលទ្ធភាពទទួលបានឱកាសទាំងនោះ? |

# សំណួរណែនាំសម្រាប់អ្នកលក់ដុំ ឈ្មួញកណ្ដាលនិងអ្នកកែច្នៃ

## ១-ព័ត៌មានទូទៅ

- ឈ្មោះ............................ភេទ.............លេខទូរស័ព្ទ.......................អ៊ីម៉ែល......................
- ហ្វេសប៊ុក........................................អាស័យដ្ឋាន ភូមិ.................. ឃុំ.............................
  ស្រុក.................................... ខេត្ត....................................
- ឈ្មោះតំបន់គោលដៅដែលអ្នកកំពុងប្រតិបត្តិការៈ
  - ភូមិ..........................................................
  - ឃុំ............................................................
  - ស្រុក.........................................................

## ២ - សំណួរណែនាំ

| | |
|---|---|
| ១ | តើផលិតផលកសិកម្មសំខាន់ៗអ្វីខ្លះដែលអ្នកកំពុងទិញ? |
| ២ | សម្រាប់មុខទំនិញនីមួយៗ តើអ្នកទិញក្នុងបរិមាណប៉ុន្មានក្នុងមួយលើកៗ? |
| ៣ | សម្រាប់មុខទំនិញនីមួយៗ សូមបញ្ជាក់ពីគុណភាពដែលអ្នកចង់បាន? |
| ៤ | ចំពោះមុខទំនិញនីមួយៗ តើអ្នកអាចទិញក្នុងបរិមាណច្រើនបំផុតប៉ុន្មាន? |
| ៥ | តើអ្នកត្រូវការផលិតផលទាំងនេះនៅពេលណា/ញឹកញាប់ប៉ុណ្ណាដែរ? |
| ៦ | តើអ្នកអាចប្រាប់ឬបញ្ជាក់ពីលក្ខខណ្ឌតម្រូវការ និងការផ្គត់ផ្គង់តាមរដូវកាលបានដែរឬទេ? (អំឡុងពេលដែលមានតម្រូវការទាប/ខ្ពស់, អំឡុងពេលដែលមានការផ្គត់ផ្គង់ទាប/ខ្ពស់)? |
| ៧ | តើអ្នកអាចប្រាប់ឬបញ្ជាក់អំពីការប្រែប្រួលតម្លៃបានទេ? (អំឡុងពេលដែលតម្លៃចុះទាប/ឡើងខ្ពស់) |
| ៨ | តើភូមិសាស្ត្រនៃតំបន់ផលិតកម្មណាដែលអ្នកអាចមើលឃើញពីលទ្ធភាពក្នុងការផ្គត់ផ្គង់ និងការដឹកជញ្ជូន? |
| ៩ | តើជម្រើសនៃការដឹកជញ្ជូនដែលអ្នកមើលឃើញមានអ្វីខ្លះ? |
| ១០ | តើអ្នកបាននិងកំពុងធ្វើការជាមួយកសិករនិង / ឬក្រុមកសិកររួចហើយឬនៅ? ប្រសិនបើមិនទាន់ទេ តើអ្នកចាប់អារម្មណ៍ក្នុងការធ្វើការឱ្យបានកាន់តែជិតស្និទ្ធជាមួយកសិករដែរឬទេ? |
| | ប្រសិនបើបានធ្វើរួចហើយ សូមពន្យល់ (តើអ្នកណា (កសិករនិង / ឬក្រុមកសិករ) នៅទីណាដែរ ច្រើនប៉ុណ្ណាដែរ ញឹកញាប់ប៉ុណ្ណា តើអ្នកពេញចិត្តដែរឬទេ)? |
| ១១ | តើអ្នកមានការរៀបចំអ្វីខ្លះជាមួយអ្នកផ្គត់ផ្គង់នាពេលបច្ចុប្បន្នរបស់អ្នក? |
| ១២ | តើអ្នកប្រឈមមុខនឹងបញ្ហាអ្វីខ្លះជាមួយក្រុមហ៊ុនផ្គត់ផ្គង់បច្ចុប្បន្នរបស់អ្នក? |
| ១៣ | តើអ្នកមានតម្រូវការអ្វីខ្លះសម្រាប់អ្នកផ្គត់ផ្គង់ថ្មី? |
| ១៤ | តើអ្នកជាបណ្ដាញនៃអ្នកបោះដុំដែរឬទេ ប្រសិនបើដូច្នេះមែន ហេតុអ្វីបានជាបណ្ដាញនេះមានសារៈសំខាន់ចំពោះអ្នក? |

| | |
|---|---|
| ១៥ | តើអ្នកមានទំនាក់ទំនងជាមួយស្ថាប័នឥណទាន / ប្រាក់កម្ចី និងសេវាកម្មផ្សេងទៀតរួច ហើយដែរឬទេ? បើដូច្នេះមែន តើនរណាខ្លះ? |
| ១៦ | តើអ្នកបានផ្តល់សេវាកម្មអ្វីខ្លះទៅឱ្យអ្នកផលិតឬអ្នកផ្គត់ផ្គង់របស់អ្នក |
| ១៧ | តើអ្នកលក់នៅឯណា ហើយលក់ឱ្យនរណា (ទីផ្សារ ឈ្មោះ ប្រភេទ ចំនួនអ្នកទិញ និងបរិមាណជាដើម) ? |
| ១៨ | តើអ្នកណាជាអ្នកកំណត់តម្លៃសម្រាប់ទំនិញរបស់អ្នក និងដោយរបៀបណា តាមប្រភេទអ្នកទិញនីមួយៗ? |
| ១៩ | តើបរិមាណនៃការលក់របស់អ្នកតាមប្រភេទអ្នកទិញ ១ ២ ៣ មួយៗយ៉ាងដូចម្តេច? (ក្នុងមួយឆ្នាំ / ខែ / រដូវ) |
| ២០ | បើប្រៀបធៀបទៅនឹងឆ្នាំមុន តើបរិមាណលក់កើនឡើងដែរឬទេ (តាមប្រភេទអ្នកទិញមួយៗ)? |
| ២១ | តើអ្នករំពឹងថាទីផ្សារនេះនឹងមានការកែប្រែឬអភិវឌ្ឍយ៉ាងដូចម្តេចនៅក្នុងរយៈពេលបីឆ្នាំទៅមុខទៀត? |
| ២២ | ប្រសិនបើមានតម្រូវការខ្ពស់ តើអ្វីដែលរារាំងអ្នកទិញមិនឱ្យទិញក្នុងបរិមាណច្រើន ឬឱ្យតម្លៃខ្ពស់? |
| ២៣ | តើអ្នកធ្វើអ្វីខ្លះដើម្បីលើកកម្ពស់/បង្កើនការលក់ផលិតផលរបស់អ្នក? |
| ២៤ | តើអ្នកជួបបញ្ហាក្នុងការលក់ផលិតផលរបស់អ្នកដែរឬទេ? ប្រសិនបើមាន តើអ្វីខ្លះ? តើអ្នកមានយោបល់ដូចម្តេចខ្លះ ដើម្បីកាត់បន្ថយបញ្ហាទាំងនេះ? |
| ២៥ | តើដំណោះស្រាយអ្វីខ្លះដែលអ្នកចង់លើកឡើងដើម្បីដោះស្រាយបញ្ហា/ឧបសគ្គទាំងនេះ និងអាចមានលទ្ធភាពទទួលឱកាសទាំងនោះបាន? |

# សំណួរណែនាំសម្រាប់ក្រុមអ្នកផលិតដែលមានសក្តានុពល

**១-ព័ត៌មានទូទៅ**

ឈ្មោះទីកន្លែង:

ចំនួនអ្នកផលិតដែលមានសក្តានុពល:

មុខទំនិញ:

អង្គភាពរបស់អ្នកផលិត: មិនមែនជាអង្គភាព សហគមន៍កសិកសម្ម ក្រុមមិនផ្លូវការ ក្រុមផ្លូវការ

## ២ - សំណួរណែនាំ

| | |
|---|---|
| ១ | តើបរិមាណផលិតផលសរុបក្នុងក្រុមសម្រាប់លក់មានប៉ុន្មាន? |
| ២ | តើអ្នកផលិតមានសហការជាមួយអ្នកផ្គត់ផ្គង់ អ្នកដើរប្រមូលទិញ ឈ្មួញកណ្តាលឬអ្នកទិញជាក់លាក់ណាដែរឬទេ?<br>ប្រសិនបើមាន សូមប្រាប់ឈ្មោះ |
| ៣ | សូមប្រាប់ឬបញ្ជាក់ពីលក្ខខណ្ឌតម្រូវការ និងការផ្គត់ផ្គង់តាមរដូវកាល (អំឡុងពេលដែលមានតម្រូវការទាប / ខ្ពស់, អំឡុងពេលដែលមានការផ្គត់ផ្គង់ទាប / ខ្ពស់)? |
| ៤ | តើសក្តានុពលផលិតកម្មជាអតិបរមាមានប៉ុន្មាន? |
| ៥ | សូមប្រាប់ឬបញ្ជាក់អំពីការប្រែប្រួលតម្លៃ? (អំឡុងពេលដែលតម្លៃចុះទាប / ឡើងខ្ពស់) |
| ៦ | តើមានបញ្ហាអ្វីខ្លះដែលជួបប្រទះក្នុងការផលិត? |
| ៧ | តើបញ្ហាប្រឈមក្នុងការលក់មានអ្វីខ្លះ? |
| ៨ | តើដំណោះស្រាយអ្វីខ្លះដែលអ្នកចង់លើកឡើងដើម្បីដោះស្រាយបញ្ហា/ឧបសគ្គទាំងនេះ និងអាចមានលទ្ធភាពទទួលឱកាសទាំងនោះបាន? |

## ៣. ប្រតិទិន

| | ខែ | | | | | | | | | | | | កំណត់ចំណាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ការដាំដុះ | | | | | | | | | | | | | |
| ការកំណត់តម្លៃ | | | | | | | | | | | | | |

# បញ្ជីរួមនៃការធ្វើផែនទីទីផ្សារ

**ខេត្ត..................................**

## I. ក្រុមអ្នកផលិត

១.១ ឈ្មោះទីកន្លែងផលិតទី១ ...............................................................................................

១.១.១ ក្រុមអ្នកផលិតទី១ ...............................................................................................

១.១.២ ក្រុមអ្នកផលិតទី២ ...............................................................................................

១.២ ឈ្មោះទីកន្លែងផលិតទី២ ...............................................................................................

## II. អ្នកលក់ធាតុចូលកសិកម្ម

២.១ ឈ្មោះទីកន្លែង**លក់ធាតុចូលកសិកម្ម**ទី១ ...............................................................................

២.១.១ អ្នកលក់ធាតុចូលកសិកម្មទី១ ...............................................................................

២.១.២ អ្នកលក់ធាតុចូលកសិកម្មទី២ ...............................................................................

២.២ ឈ្មោះទីកន្លែងលក់ធាតុចូលទី២ ...............................................................................

## III. អ្នកទិញដុំ

២.១ ឈ្មោះទីកន្លែងទិញដុំទី១ ...............................................................................................

២.១.២ អ្នកទិញដុំទី១ ...............................................................................................

២.១.២ អ្នកទិញដុំទី២ ...............................................................................................

២.២ ឈ្មោះទីកន្លែងទិញដុំទី២ ...............................................................................................

# បញ្ជីសម្រាំងក្រុមដែលមានសក្តានុពល

**ខេត្ត................................**

**I. ក្រុមទី ១**

១.១ ឈ្មោះទីកន្លែង ..............................................................................................................

១.២ ក្រុមអ្នកផលិត ..............................................................................................................

១.៣ ក្រុមអ្នកផ្គត់ផ្គង់វត្ថុធាតុដើម ....................................................................................

១.៤ អ្នកទិញដុំ ......................................................................................................................

១.៥ បញ្ហា ..............................................................................................................................

១.៦ ដំណោះស្រាយមានសក្តានុពល ....................................................................................

**I. ក្រុមទី ២**

១.១ ឈ្មោះទីកន្លែង ..............................................................................................................

១.២ ក្រុមអ្នកផលិត ..............................................................................................................

១.៣ ក្រុមអ្នកផ្គត់ផ្គង់វត្ថុធាតុដើម ....................................................................................

១.៤ អ្នកទិញដុំ ......................................................................................................................

១.៥ បញ្ហា ..............................................................................................................................

១.៦ ដំណោះស្រាយមានសក្តានុពល ....................................................................................

# បញ្ជីឈ្មោះតួអង្គចូលរួមក្នុងការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា

ក្រុម............................

## I. អ្នកទិញយកទៅបោះដុំ

| ល.រ | អ្នកទិញយកទៅបោះដុំ | ព័ត៌មានទំនាក់ទំនង | បញ្ជីរាយមុខទំនិញ | ចំនួន/បរិមាណត្រូវទិញ | សេវាកម្មដែលនឹងមានផ្តល់ជូន |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## II. អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម

| ល.រ | អ្នកផ្គត់ផ្គង់ធាតុចូល | ព័ត៌មានទំនាក់ទំនង | បញ្ជីរាយមុខវត្ថុធាតុដើម | តម្លៃ | សេវាកម្មដែលនឹងមានផ្តល់ជូន |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

**បោះពុម្ពលើកទី១ ឆ្នាំ២០១៨ ដោយ**

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

អាសយដ្ឋាន ២០០ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា

( ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ )

គេហទំព័រ WWW.ASPIREKH.ORG និង WWW.KHMERAGRI.INFO